USAID FROM THE AMERICAN PEOPLE

fhi360

LEGAL AID of CAMBODIA

# កំណត់សំគាល់ ផ្នែកច្បាប់

# ស្តីពី

# អធិការកិច្ចការងារ

# សម្រាប់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ( NGOs )

## សេចក្តីផ្តើម

អធិការការងារ និងអភិបាលការងារ ត្រូវស្បថថានឹងបំពេញភារកិច្ចរបស់ខ្លួន ដោយល្អ ដោយស្វាមីភក្តិនិងមិនប្រាប់ឱ្យគេដឹងនូវអាថ៌កំបាំងផលិតកម្ម ពាណិជ្ជ របៀបធ្វើអាជីវកម្ម ដែលខ្លួនបានដឹងឮ ក្នុងពេលបំពេញមុខងាររបស់ខ្លួន ទោះបីខ្លួនចេញពីក្រសួងហើយក្តី ។

អធិការកិច្ចពេទ្យការងារ ធ្វើសកម្មភាពជាអចិន្ត្រៃយ៍ក្នុងគោលដៅ ការពារសុខភាពកម្មករនិយោជិតនៅកន្លែងធ្វើការ ។ ភារកិច្ចនៃអធិការកិច្ចនេះ ត្រូវប្រគល់ឱ្យអធិការពេទ្យការងារ ដែលត្រូវចាប់អារម្មណ៍ជាពិសស ទៅលើសកម្មភាពរៀបចំនិងដាក់ឱ្យដំណើរការសេវាពេទ្យការងារ ។

អធិការពេទ្យការងារបំពេញការងារដោយសម្ព័ន្ធការ ជាមួយអធិការការងារ និងសហការជាមួយគ្នាលើការអនុវត្តន៍បទបញ្ជាទាំងឡាយ ទាក់ទងដល់សុខភាពនៃកម្មករនិយោជិត ។

ក្នុងក្របខ័ណ្ឌនៃបេសកកម្មរបស់ខ្លួន បទប្បញ្ញត្តិនានាដែលទាក់ទងដល់សិទ្ធិអំណាច និងកាតព្វកិច្ចអធិការការងារដែលកំណត់ក្នុងច្បាប់ការងារ ក៏ត្រូវប្រគល់ជូនអធិការពេទ្យការងារដែរ ។

## បេសកកម្មអធិការកិច្ចការងារ

អធិការកិច្ចការងារត្រូវមានបេសកកម្មជាអាទិ៍ដូចតទៅ :

១. ធានាដល់ការអនុវត្តន៍ច្បាប់ការងារ និងអត្ថបទអនុវត្តច្បាប់ ដែលបានគ្រោងទុក ក៏ដូចជាច្បាប់និងបទបញ្ជាច្បាប់ដទៃទៀត ដែលមិនទាន់បានចងក្រង ហើយដែលមានការទាក់ទងដល់របបការងារ ។

២.ផ្តល់ដំណឹងនិងដំបូន្មានបច្ចេកទេសចំពោះនិយោជក និង កម្មករនិយោជិត អំពីមធ្យោបាយ ដ៏មានប្រសិទ្ធិភាពដើម្បីគោរពបទប្បញ្ញត្តិ ច្បាប់ ។

៣.ផ្តល់ពតិមានទៅអាជ្ញាធរមានសមត្ថកិច្ចនូវការមិនគប្បីឬការរំលោភផ្សេងៗដោយហេតុមកពីពុំទាន់មានបទប្បញ្ញត្តិច្បាប់ជាធរមាន ។

៤.ជូនយោបល់ អំពីបញ្ហាទាក់ទងនឹងការរៀបចំ ឬកែប្រែសហគ្រាស និងអង្គការចាត់តាំងដែលបានអនុញ្ញាតអំពីអាជ្ញាធររដ្ឋបាល ហើយដែលមានចង្អុលក្នុងច្បាប់ជាធរមាន ។

៥.ត្រួតពិនិត្យការអនុវត្តន៍បទប្បញ្ញត្តិ ដែលទាក់ទងនិងល័ក្ខខ័ណ្ឌជីវភាពនៃកម្មករនិយោជិត និងគ្រួសារជនទាំងនេះ ។[1]

## មុខងារអធិការការងារ និងអភិបាលការងារ

អធិការការងារ និងអភិបាលការងារដែលមានលិខិតជាភស្តុតាង បង្ហាញនូវមុខងារខ្លួនត្រូវអនុញ្ញាត្តិដូចខាងក្រោម ៖

១.ចូលដោយសេរីទៅក្នុងសហគ្រាសទាំងអស់ដែលនៅក្រោមអំណាចត្រួតពិនិត្យរបស់អធិការដ្ឋានដោយមិនបាច់ប្រាប់នូវពេលម៉ោង ទោះថ្ងៃក្តី យប់ក្តី ។

២.ចូលពេលថ្ងៃទៅក្នុងទីស្ថានទាំងអស់ ដែលខ្លួនអាចសន្និដ្ឋានដោយមានមូលហេតុ សមរម្យ ថាគួរឱ្យមានការត្រួតពិនិត្យនៃអធិការដ្ឋាន ។

៣.ចាត់ការពិនិត្យផ្សេងៗ ត្រួតពិនិត្យ និងអង្កេត ដែលយល់ថាជាការចាំបាច់ ដើម្បីឱ្យ ដឹងជាក់ច្បាស់ថា បទប្បញ្ញត្តិ ត្រូវបានគោរពហ្មត់ចត់ ហើយមានជាអាទិ៍ :

- ការសួរនិយោជក ឬបុគ្គលិកសហគ្រាស ម្នាក់ឯង ចំពោះមុខសាក្សីក្តី , អំពីរឿងទាក់ទងនឹងការអនុវត្តន៍បទប្បញ្ញត្តិច្បាប់ ។
- ការទារឱ្យប្រគល់យកមកពិនិត្យនូវសៀវភៅបញ្ជីកា និងឯកសារដែលនិយោជកត្រូវតែមានតាមបទប្បញ្ញត្តិច្បាប់ស្តីពីល័ក្ខខ័ណ្ឌការងារ ដើម្បីផ្ទៀងមើល តើត្រឹមត្រូវតាមបទ

[1] មាត្រា ៣៤៤ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

ប្បញ្ញត្តិច្បាប់ហើយឬនៅ ព្រមទាំងមានសិទ្ធិចម្លងឬស្រង់សេចក្តីផ្សេងៗចេញពីសៀវភៅឬបញ្ជិកានោះ។

- បង្គាប់ឱ្យបិទផ្សាយនូវប្រកាស ឬអ្វីៗដែលច្បាប់តម្រូវឱ្យបិទផ្សាយ ។
- ហូត ឬដកយកគំរូ នៃវត្ថុធាតុ ឬសារជាតិដែល ប្រើប្រាស់ ឬវត្ថុលាយ មកធ្វើវិភាគ ឱ្យតែនិយោជក ឬតំណាងនៃជននេះបានដឹងថា វត្ថុធាតុ ឬសារជាតិនេះបានហូត ឬ ដកដើម្បីការងារ នេះប៉ុណ្ណោះ ។

ក្នុងការត្រួតពិនិត្យម្តងៗ អធិការ ឬអភិបាលការងារ ត្រូវប្រាប់វត្តមានខ្លួនទៅនិយោជក ឬអ្នកតំណាង លើកលែងតែករណីដែលខ្លួនយល់ឃើញថា ការប្រាប់ឱ្យដឹងមុន នាំឱ្យខូចប្រសិទ្ធិភាពនៃការត្រួតពិនិត្យ ។

អធិការការងារ និងអភិបាលការងារ អាចហៅប្រតិភូបុគ្គលិកម្នាក់ឬច្រើននាក់ ឱ្យដើរជាមួយខ្លួន ក្នុងការត្រួតពិនិត្យការងារនោះផងដែរ ។[2]

## អំណាចអធិការការងារ និងអភិបាលការងារ

អធិការការងារ និងអភិបាលការងារមានអំណាចដូចខាងក្រោម ៖

១.ធ្វើកំណត់សំគាល់ ទៅឱ្យនិយោជក ឬតំណាងនៃជននេះ និងទៅឱ្យកម្មករនិយោជិត ។

២.ដាក់កំហិតនិយោជក ឬអ្នកតំណាងជននេះឱ្យចាត់ការក្នុងការគោរពបទប្បញ្ញត្តិច្បាបឱ្យបានទាន់ក្នុងរយៈពេលដែលខ្លួនកំណត់ ។

៣.កត់សម្គាល់នូវការ មិនគោរពបទប្បញ្ញត្តិ ដោយធ្វើកំណត់ហេតុដែលគេត្រូវតែជឿរហូតដល់ មានភស្តុតាងផ្ទុយ ។

៤.បង្គាប់ឱ្យចាត់ ឬប្រើឱ្យចាត់វិធានការដែលត្រូវប្រតិបត្តិភ្លាមៗ កាលណាមានមូលហេតុសមរម្យដែលកត់សំគាល់ឃើញ ឬសន្និដ្ឋានថាមានគ្រោះថ្នាក់ពិតប្រាកដហើយធ្ងន់ធ្ងរចំពោះសុខភាព ឬសន្តិសុខចំពោះកម្មករនិយោជិត ។

៥.សំរេចធ្វើការពិន័យ ចំពោះអ្នកប្រព្រឹត្តល្មើសនិងបទប្បញ្ញត្តិទាំងឡាយ នៃច្បាប់ការងារ និងអត្ថបទអនុវត្តបទប្បញ្ញត្តិទាំងនោះ ។[3]

---

[2] មាត្រា ៣៤៦ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[3] មាត្រា ៣៤៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

## ស្វ័យប្រកាសអធិការកិច្ចការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារនិងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីគ្រប់គ្រងទិន្នន័យអធិការកិច្ចការងារនៅកម្ពុជាតាមប្រព័ន្ធស្វ័យប្រវត្តិកម្មតាមរយៈគេហទំព័រ ខាងក្រោម៖ https://sicms.mlvt.gov.kh/ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២។

ម្ចាស់ឬនាយករោងចក្រ សហគ្រាស ត្រូវបំពេញនូវព័ត៌មានក្នុងរបាយការណ៍នៃរបបស្វ័យប្រកាស អធិការកិច្ចការងារក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ចំនួន ២ (ពីរ) លើកក្នុងមួយឆ្នាំ គឺលើកទី១ នៅក្នុងខែមិថុនា និង លើកទី២ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ និងត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងរបាយការណ៍នៃរបបស្វ័យប្រកាសអធិការកិច្ចការងារឱ្យបានរួចរាល់ មុនកាលបរិច្ឆេទនៃការចុះធ្វើអធិការកិច្ចការងារសាមញ្ញរបស់អធិការការងារ។

អធិការការងារនឹងធ្វើអធិការកិច្ចការងារសាមញ្ញតែមួយលើកក្នុងមួយឆ្នាំនៅតាមរោងចក្រ សហគ្រាស លើកលែងតែអធិការកិច្ចការងារពិសេស តាមដានការដាក់កំហិត តាមបណ្តឹង ឬទទួលបានព័ត៌មានអំពីការរំលោភ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។[4]

## សេចក្តីសន្និដ្ឋាន

របបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មត្រូវបានរៀបចំឡើងក្នុងគោលបំណងតម្រូវឱ្យម្ចាស់ ឬនាយករោងចក្រ សហគ្រាសធ្វើការត្រួតពិនិត្យដោយខ្លួនឯងជាមុននូវការអនុវត្តច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

ការធ្វើអធិការកិច្ចការងារជាការអនុវត្តកាតព្វកិច្ចតាមច្បាប់ដោយក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថាន និងមិនរងការផាកពិន័យទៅតាមច្បាប់កំណត់។

ឯកសារយោងដែលជាមូលដ្ឋានគឺ ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧ និង ប្រកាសលេខ ៣៨៥/២១ កប/ប្រក អ.ធ.ក ចុះថ្ងៃទី ៣០ខែធ្នូ ឆ្នាំ២០២១ ស្តីពី ការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[4] ប្រកាសលេខ ៣៨៥/២១ កប/ប្រក អ.ធ.ក ចុះថ្ងៃទី ៣០ខែធ្នូ ឆ្នាំ២០២១

ការមិនអនុវត្តតាមច្បាប់ជាធរមាននិងត្រូវអនុវត្តទណ្ឌកម្មតាមប្រកាសរួមលេខ ៦៩៥ សហវ/ប្រក ស្តីពីការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការងារ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**សេចក្តីបញ្ជាក់**

អត្ថបទបង្ហាញនេះ បានធ្វើឡើងដោយមានការឧបត្ថម្ភសប្បុរសធម៌ពីប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ មាតិកានៃបទបង្ហាញនេះជាការទទួលខុសត្រូវរបស់អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ FHI 360 ឬ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។